00718559

E95/3

| ឯកសារដើម |
|---|
| DOCUMENT RECEIVED/DOCUMENT REÇU |
| ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 22 / 07 / 2011 |
| ម៉ោង (Time/Heure): 13:40 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun |

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក- (អ.ជ.ស.ប.)

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ២២ កក្កដា ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ស.ប៖ **សាធារណៈ / Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាដែលបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងលុបចោលនូវលក្ខណៈវិនិច្ឆ័យដែលដាក់បញ្ចូលជម្លោះប្រដាប់អាវុធទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក ស សុវាន

លោក Jacques VERGES

**អ្នកជំនួយការ**

លោកស្រី សេង សុជាតា

<u>ផ្ញើជូន</u>៖

**អង្គបុរេជំនុំជម្រះ**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម Silvia CARTWRIGHT

លោកស្រី Marie CAPOTORTO

លោក Shéhérazade BOUARFA

លោក Archibald CELEYRON

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី Elisabeth SIMONNEAU FORT

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## I. សេចក្តីផ្តើម

១. កាលពីថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានកែប្រែដីកាដំណោះស្រាយ[1] ដោយអង្គបុរេជំនុំជម្រះបានដាក់បន្ថែមនូវ "លក្ខខណ្ឌអត្ថិភាពនៃចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធទៅក្នុងផ្នែកទី IV (ក) នៃជំពូក៣ នៃដីកាដំណោះស្រាយ ដែលមានចំណងជើងថាធាតុផ្សំរួម" [2]។

២. យោងទៅលើវិធាន ៨៩ នៃវិធានផ្ទៃក្នុង ភាគីដែលមានបំណងចង់លើកឡើងនូវករណីអញ្ញត្រកម្មទាក់ទងទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវលើកឡើង "យ៉ាងយូរ ៣០ ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ"។ លោក ខៀវ សំផន បានដាក់អញ្ញត្រកម្មរបស់ខ្លួនកាលពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១[3]។

៣. កាលពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[4]។ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យមេធាវីការពារក្តី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋ

---

[1] ដីកាដំណោះស្រាយ, ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ *ឯកសារតុលាការ* D427។

[2] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, ("សាលដីកា ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១") *ឯកសារតុលាការ* D427/4/14។

[3] អញ្ញត្រកម្មបឋមលើយុត្តាធិការ, ("អញ្ញត្រកម្មបឋម") *ឯកសារតុលាការ* E46។

[4] សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូង ដកល័ក្ខខ័ណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ("សំណើរបស់សហព្រះរាជអាជ្ញា"), ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ *ឯកសារតុលាការ* E95 ។ ការជូនដំណឹងធ្វើឡើងថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ វេលាម៉ោង ១០.៤៨ នាទី។ ការបកប្រែត្រូវបានស្នើសុំ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ម៉ោង ១០.៥៣ នាទី សម្រាប់យកថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១១ និងជូនដំណឹងថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១។

ប្បវេណីដាក់ចម្លើយតបរបស់ខ្លួនយ៉ាងយូរបំផុតត្រឹមថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ប្រសិនបើមានបំណងធ្វើការឆ្លើយតប[5]។

៤. កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ លោក អៀង សារី បានស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងចេញសេចក្ដីសម្រេចបន្ទាន់មួយ ពាក់ព័ន្ធទៅនឹងភាពដែលអាចទទួលយកបាននៃសំណើសុំនេះ (ក្នុងចំណោមសំណើសុំឯទៀត) ក្នុងដំណាក់កាលនៃនីតិវិធីនេះ[6]។

៥. មកទល់ពេលនេះ អង្គជំនុំជម្រះសាលាដំបូងនៅតែពុំទាន់បានធ្វើការសម្រេចលើសំណើសុំនេះនៅឡើយ។

## II. ការដេញដោល ៖ ភាពមិនអាចទទួលយកបាននៃសំណើសុំរបស់សហព្រះរាជអាជ្ញា

៦. សំណើសុំរបស់សហព្រះរាជអាជ្ញាមិនអាចទទួលយកបានឡើយ ហើយត្រូវតែបានបដិសេធចោលតាំងពីដំបូងទី (*in limine*)។ ជាក់ស្ដែង សំណើសុំនេះត្រូវបានដាក់ ដោយអនុវត្តនូវវិធាន ៩២ និង ៩៨ (២) នៃវិធានផ្ទៃក្នុង"[7] ដែលវិធានទាំងពីរនេះមិនអាចអនុវត្តបានឡើយ ពោលគឺខុសអំពីវិធាន ៨៩ ដែលតាមរយៈវិធាននេះ សហព្រះរាជអាជ្ញាបានបាត់បង់សិទ្ធរបស់ខ្លួនហើយ។

៧. វិធាន ៩៨ ដែលបានចំណងជើងថា "សាលក្រម" មិនអាចត្រូវបានប្រើជាមូលដ្ឋានគតិយុត្តិសម្រាប់ឱ្យបណ្ដឹងរបស់សហព្រះរាជអាជ្ញាអាចទទួលយកបាននោះឡើយ។ វិធាននោះបានចែងថា៖

> "២. សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូន

---

[5] សេចក្ដីសម្រេចលើសំណើសុំពន្យារពេល, ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១ *ឯកសារតុលាការ* E107។

[6] សំណើរបស់ អៀង សារី សុំឱ្យមានសេចក្ដីសម្រេចជាបន្ទាន់ទាក់ទងនឹងបញ្ហាថា តើសហព្រះរាជអាជ្ញា អាចស្នើសុំឱ្យផ្លាស់ប្ដូរការកំណត់បទចោទ នៅដំណាក់កាលនេះនៃនីតិវិធី ដែរ ឬ អត់ និងសំណើសុំពេលវេលាបន្ថែម ដើម្បីឆ្លើយតបទៅនឹងសំណើសុំនានាទាំងនេះ បើសិនជាចម្លើយតបជាការចាំបាច់, ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E103។ លើចំណុចនេះ សូមមើល សារតារនីតិវិធី ពាក់ព័ន្ធនឹងសំណើសុំនានារបស់លោក អៀង សារី។

[7] សំណើរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ១។

រឿងទៅជំនុំជម្រះប៉ុណ្ណោះ ។ អង្គជំនុំជម្រះអាចផ្លាស់ប្ដូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ (...)

៣. អង្គជំនុំជម្រះត្រូវពិនិត្យថា តើអំពើនោះជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងថាតើជនជាប់ចោទបានប្រព្រឹត្តអំពើនោះដែរឬទេ។

(...)

៧. នៅពេលដែលអង្គជំនុំជម្រះយល់ឃើញថា បទល្មើសដែលកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នោះអង្គជំនុំជម្រះត្រូវសម្រេចថា គ្មានសមត្ថកិច្ចទៅលើករណីនោះទេ។

៨. កថាខណ្ឌ ២ អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែពុំបានអនុញ្ញាតដល់សហព្រះរាជអាជ្ញាឡើយ ក្នុងការផ្លាស់ប្ដូរការកំណត់បទចោទ ក្នុងដំណាក់កាលនៃការចេញសាលក្រម “ក្នុងករណីដែលមិនមានដាក់បញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទនោះ”។ ក្នុងដំណាក់កាលនៃការចេញសាលក្រមលើសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា បទបញ្ញត្តិនេះគឺជា “ការដាក់កម្រិតដល់អំណាចក្នុងការកំណត់សាជាថ្មីនូវបទចោទ ពោលគឺការផ្លាស់ប្ដូរការកំណត់បទចោទថ្មីណាមួយមិនត្រូវធ្វើឲ្យលើសពីអង្គហេតុទាំងឡាយណាដែលមានបង្ហាញនៅក្នុងឯកសារចោទប្រកាន់នោះទេ”[8]។ អង្គជំនុំជម្រះសាលាដំបូងក៏បានបន្ថែមទៀតផងដែរថា “វិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងផ្លាស់ប្ដូរការកំណត់បទចោទ បន្ទាប់ពីពេលចាប់ផ្ដើមដំណើរការនីតិវិធីជំនុំជម្រះ”[9]។

[8] សាលក្រមក្នុងសំណុំរឿង ឌុច, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ *ឯកសារតុលាការ* E188 កថាខណ្ឌ៤៩៤។

[9] សាលក្រមក្នុងសំណុំរឿង ឌុច, កថាខណ្ឌ៤៩៥ (មិនមានគូសបន្ទាត់ក្នុងឯកសារដើម)។

៩. បទដ្ឋាន ៥៥ នៃវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានលើកឡើងជាឯកសារយោង ចែងថា៖

"១. ដោយមិនធ្វើឱ្យលើសអំពីអង្គហេតុ និងកាលៈទេសៈដែលមានបង្ហាញនៅក្នុងឯកសារចោទប្រកាន់ និងក្នុងឯកសារកែប្រែអង្គហេតុណាមួយ អង្គជំនុំជម្រះអាចធ្វើការផ្លាស់ប្តូរ តាមរយៈសេចក្តីសម្រេចរបស់ខ្លួនស្របទៅនឹងមាត្រា ៧៤ នូវការកំណត់បទចោទ ដើម្បីឱ្យអង្គហេតុមានភាពស៊ីសង្វាក់គ្នាទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដូចមានចែងក្នុងមាត្រា (...)

២. ប្រសិនជានៅក្នុងដំណាក់កាលណាមួយនៃការជំនុំជម្រះ អង្គជំនុំជម្រះយល់ឃើញថា ការកំណត់បទចោទអាចត្រូវបានផ្លាស់ប្តូរ អង្គជំនុំជម្រះត្រូវធ្វើការជូនដំណឹងដល់ភាគី នៃនីតិវិធីអំពីលទ្ធភាពនេះ ហើយបន្ទាប់ពីបានពិនិត្យលើធាតុផ្សំនៃភស្តុតាង អង្គជំនុំជម្រះត្រូវផ្តល់លទ្ធភាព ក្នុងពេលវេលាមួយសមស្រប ដល់ភាគីក្នុងការធ្វើកំណត់សម្គាល់ផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ (...)[10]។

១០. នៅពេលអានវិធាន ៩៨ នៃវិធានផ្ទៃក្នុង បទដ្ឋាន ៥៥ នៃវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងមាត្រា ៧៤ នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ វាជាក់ច្បាស់ណាស់ថា ចៅក្រមអាចធ្វើការកំណត់បទចោទសាជាថ្មីនៅក្នុងដំណាក់កាលសវនាការលើអង្គសេចក្តី។ ការកំណត់បទចោទសាជាថ្មី ដោយយោងទៅលើការពិនិត្យភស្តុតាង អាចអនុញ្ញាតឱ្យអង្គហេតុមានភាព**ស៊ីសង្វាក់គ្នា**ទៅនឹងការកំណត់បទចោទដែលត្រឹមត្រូវបំផុត ពោលគឺការកំណត់បទចោទដែលមានលក្ខណៈត្រឹមត្រូវបំផុត ត្រូវបានកំណត់ត្រឹមត្រូវតាមច្បាប់ និងស្ថិតក្នុងយុត្តាធិការនៃសាលាជម្រះក្តី។ ក្នុងករណីផ្សេងពី

---

[10] មាត្រា ៧៤ នៃលក្ខន្តិកៈទីក្រុងរ៉ូម ("អំពីល័ក្ខខ័ណ្ឌតម្រូវសម្រាប់សេចក្តីសម្រេច") ចែងនៅក្នុងកថាខណ្ឌ២ ថា៖ "សេចក្តីសម្រេចរបស់សភាជំនុំជម្រះ ត្រូវផ្អែកលើការវាយតម្លៃរបស់ខ្លួន លើភ័ស្តុតាង និងដំណើរការជម្រះរឿងក្តីទាំងមូល។ សេចក្តីសម្រេចមិនត្រូវធ្វើឱ្យហួសពីអង្គហេតុ និងកាលៈទេសៈដែលបានពណ៌នានៅក្នុងបទចោទប្រកាន់ និងក្នុងការកែប្រែបទចោទប្រកាន់នានា។ តុលាការអាចផ្អែកលើសេចក្តីសម្រេចរបស់ខ្លួន តែទៅលើភ័ស្តុតាងដែលបានដាក់ជូន និងបានពិភាក្សានៅចំពោះមុខតុលាការក្នុងពេលជំនុំជម្រះប៉ុណ្ណោះ"។

នេះ សាលាជម្រះក្តីត្រូវប្រកាសយ៉ាងសាមញ្ញថា ខ្លួនគ្មានយុត្តាធិការទៅលើរឿងនេះឡើយ។

១១. ការកំណត់បទចោទសាជាថ្មីគឺជាប្រតិបត្តិការមួយ ដែលចៅក្រមផ្តល់នូវការកំណត់ត្រឹមត្រូវចំពោះទង្វើ ឬអង្គហេតុណាមួយ ពោលគឺពុំមែនជាប្រតិបត្តិការដែលចៅក្រមអាចកែប្រែនិយមន័យគតិយុត្តិនៃបទល្មើស ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួនឡើយ។

១២. ដោយឡែក ប្រហែលជាផ្អែកទៅលើប្រតិបត្តិការក្រោយនេះហើយ ដែលសហព្រះរាជអាជ្ញាបានស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងសម្រេចតាមសំណើសុំរបស់ខ្លួន។ សហព្រះរាជអាជ្ញាស្នើសុំដល់អង្គជំនុំជម្រះសម្រេចអំពី**ច្បាប់ដែលត្រូវអនុវត្ត**ទៅលើសាលាជម្រះក្តី ដោយស្នើសុំឲ្យអង្គជំនុំជម្រះលុបចោលលក្ខណៈវិនិច្ឆ័យ ដែលដាក់បញ្ចូលជម្លោះប្រដាប់អាវុធទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

១៣. ក្នុងករណីជាក់ស្តែង វិធាន ៩៨ (២) ពុំត្រូវបានអនុវត្តឡើយ គឺដូចគ្នាទៅនឹងវិធាន ៩២ ដែរ[11]។ ផ្ទុយទៅវិញ បទបញ្ញត្តិពិសេសអនុញ្ញាតឲ្យភាគីធ្វើការស្នើសុំដល់អង្គជំនុំជម្រះឲ្យធ្វើការកំណត់និយមន័យគតិយុត្តិនៃបទល្មើស ឬនៃបែបផែននៃការចូលរួម របស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែ ពោលគឺកំណត់អំពីច្បាប់ដែលអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះ៖ ករណីនេះពាក់ព័ន្ធទៅនឹងវិធាន ៨៩ ដែលចែងអំពីអញ្ញត្រកម្មយុត្តាធិការរបស់ អ.វ.ត.ក.។ មានតែវិធាន ៨៩ និងគោលការណ៍នីត្យានុកូលភាពមួយគត់ ដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋានដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃទៅលើបទល្មើស និងបែបផែននៃការចូលរួមដូចដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ថាតើស្ថិតនៅក្រោម ឬមិនស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួននោះ។

---

[11] ទោះបីជាវិធាន ៩២ អនុញ្ញាតឲ្យភាគីដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ រហូតដល់ពេលបិទបញ្ចប់ការពិភាក្សាដេញដោលក៏ដោយ ក៏វិធាននេះមិនបានបញ្ជាក់ពីប្រភេទនៃសេចក្តីសន្និដ្ឋានបែបណាដែរ។ វិធាននេះជាបញ្ញត្តិទូទៅ ដែលត្រូវអនុវត្តនៅពេលពុំមានបញ្ញត្តិពិសេស។

១៤. ជាក់ស្តែង ការស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការសម្រេចអំពីអត្ថិភាពនៃចំណងពាក់ព័ន្ធជាមួយនឹងជម្លោះប្រដាប់អាវុធក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយផ្អែកលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ បានសេចក្តីថា ស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការសម្រេចអំពីច្បាប់ដែលត្រូវអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះ ហើយស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះ។ ចំណុចនេះរឹតតែមានលក្ខណៈច្បាស់លាស់ បើយើងផ្អែកទៅលើយុត្តិសាស្ត្រអន្តរជាតិ[12]។

១៥. ជាក់ស្តែង សហព្រះរាជអាជ្ញាពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការដាក់នូវអញ្ញត្រកម្មបឋមរបស់ខ្លួនពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះក្នុងរយៈពេល ៣០ ថ្ងៃ នៅឡើយទេ ដែលបន្ទាប់ពីផុតរយៈពេលនោះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងចូលជាស្ថាពរ ដូចបានកំណត់ក្នុងវិធាន ៨៩ នៃវិធានផ្ទៃក្នុង "ផុតរយៈពេលនេះ អញ្ញត្រកម្មបឋមមិនអាចទទួលយកបានឡើយ"។ ជាក់ស្តែង សំណើសុំរបស់សហព្រះរាជអាជ្ញាត្រូវបានដាក់កាលពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ពោលគឺមាន រយៈពេលជាងបួនខែក្រោយរយៈពេលផុតកំណត់ដែលចែងដោយវិធានផ្ទៃក្នុង។ ដូច្នេះសំណើសុំនោះ មិនអាចទទួលយកបានឡើយ។

១៦. ដោយឡែក នៅក្នុងចម្លើយតបរួមគ្នារបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាដំណោះស្រាយ សហព្រះរាជអាជ្ញាបានស្នើសុំដល់អង្គបុរេជំនុំជម្រះបដិសេធចោលមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដែល

---

[12] ឧទាហរណ៍សូមមើល៖ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី (« TPIY »), រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Vojislav SESELJ*, សំណុំរឿងលេខ IT-03-67-AR72.1, *សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ពាក់ព័ន្ធនឹងអញ្ញត្រកម្មយុត្តាធិការ*, ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤។ នៅក្នុងសាលដីកានេះ អង្គជំនុំ ជម្រះ តុលាការកំពូលបានពិនិត្យ**និយមន័យនៃពាក្យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ៖** "ដូចដែលបានបញ្ជាក់ដោយយុត្តិសាស្ត្ររបស់តុលាការពាក់ព័ន្ធនឹងយុត្តាធិការ មាត្រា ៥ នៃលក្ខន្តិក តម្រូវឱ្យមានអត្ថិភាព ជម្លោះប្រដាប់អាវុធនៅសម័យនោះ និងនៅតាមទីកន្លែងដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (...) ដូចគ្នានេះដែរ ការបកស្រាយខាងលើរបស់ អង្គជំនុំជម្រះតុលាការកំពូល ក្នុងរឿងក្តី *Tadic* ស្តីពីការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ ដែលនៅ ក្នុងនោះមានចែងពីមាត្រា ៥ នៃលក្ខន្តិក គឺជាការបកស្រាយទូលំទូលាយស្តីពីការតម្រូវពាក់ព័ន្ធនឹងការអនុវត្តយុត្តាធិការដែលថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងនៅពេលមានជម្លោះប្រដាប់អាវុធ" កថាខណ្ឌ១៣, មិនមានគូសបន្ទាត់ពីក្រោម ក្នុងឯកសារដើម។

តាមរយៈនោះ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានចំណងពាក់ព័ន្ធជាមួយជម្លោះប្រដាប់អាវុធ ដោយហេតុថា អញ្ញត្រកម្មនេះមានទៅលើអាជ្ញាយុកាល[13]។ សហព្រះរាជអាជ្ញាមិនអាចអះអាងបានទេថារយៈពេលសម្រាប់មេធាវីការពារក្ដីក្នុងការលើកអញ្ញត្រកម្មនេះបានផុតកំណត់ជាង ៣ ឆ្នាំ មកហើយ ប៉ុន្តែខ្លួនបែរជាលើកបញ្ហានេះក្នុងអំឡុងពេល ៨ ខែ ក្រោយទៅវិញ។

១៧. ជាក់ស្ដែង សហព្រះរាជអាជ្ញាមានបំណងធ្វើបណ្ដឹងឧទ្ធរណ៍ "ក្លែងក្លាយ" ប្រឆាំងទៅនឹងដីកាដំណោះស្រាយ និងប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ ពាក្យបណ្ដឹងឧទ្ធរណ៍ក្លែងក្លាយនេះ គឺជាពាក្យដែលសហព្រះរាជអាជ្ញាធ្លាប់ប្រើប្រាស់នៅ ពេលដែលខ្លួនបានស្នើសុំឱ្យ "អង្គជំនុំជម្រះសាលាដំបូងធ្វើការ<u>កែប្រែ</u>និយមន័យគតិយុត្តិនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយ និងកែប្រែដោយអង្គបុរេជំនុំជម្រះ ហើយស្នើសុំឱ្យអង្គជំនុំជម្រះលុបចោលលក្ខខណ្ឌចំណងពាក់ព័ន្ធរវាងឧក្រិដ្ឋកម្មសង្គ្រាមទៅនឹងជម្លោះប្រដាប់អាវុធនោះ[14]"។

១៨. ដោយឡែក អង្គបុរេជំនុំជម្រះបានរំលឹកតាមរយៈសេចក្ដីសម្រេចរបស់ខ្លួន ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ថា៖ "ដោយអនុវត្តវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចនេះជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា"។សហព្រះរាជអាជ្ញាក៏បានទទួលស្គាល់ចំណុចនេះផងដែរ ដោយបានលើកឡើងកាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ក្នុងសវនាការសម្រេចអំពីការដោះលែងឱ្យនៅក្រៅឃុំ ថា៖

---

[13] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ *ឯកសារតុលាការ* D427/3/6 កថាខណ្ឌ៣៥ ដល់ កថាខណ្ឌ៤២។

[14] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១ ដែលមិនមានគូសបន្ទាត់ពីក្រោមនៅក្នុងឯកសារដើម។ សំណើនេះមានទម្រង់ជាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសាលដីការបស់អង្គបុរេជំនុំជម្រះ ដែលត្រូវបានលើកឡើងចំនួនដប់ប្រាំដង។ សូមមើលផងដែរ ផ្នែកសេចក្ដីសន្និដ្ឋាន កថាខណ្ឌ៣៣ ដែលសហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង "ធ្វើវិសោធនកម្មលើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយ ដែលបានកែប្រែដោយមិនរាប់បញ្ចូលនូវល័ក្ខខ័ណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ដែល<u>អង្គបុរេជំនុំជម្រះ</u>បានដាក់បន្ថែម" (មិនមានគូសបន្ទាត់ពីក្រោម នៅក្នុងឯកសារដើម)។

"សំណើសុំនេះមិនអាចទទួលយកបានឡើយ ដោយហេតុថាសំណើសុំនេះបានស្នើសុំឱ្យអង្គសវនាការធ្វើការពិនិត្យឡើងវិញលើសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ហើយស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការកំណត់អំពីសុពលភាពនៃសេចក្ដីសម្រេចនេះ ដែលចេញថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។

វិធានផ្ទៃក្នុងរបស់តុលាការ នៅត្រង់វិធាន៧៧ (១៣) បានចែងយ៉ាងច្បាស់ថា សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា ហើយគេពុំចាំបាច់ធ្វើការបញ្ជាក់នៅទីនេះថា អង្គជំនុំជម្រះសាលាដំបូងពុំត្រូវបានបង្កើតក្នុង ក្របខណ្ឌនៃវិធានផ្ទៃក្នុង ឱ្យដើរតួនាទីជាសាលាឧទ្ធរណ៍នោះទេ។ យើងសូមប្រកាសថា ទោះបីជាមានការយល់ឃើញថា ទឡ្ហីករណ៍ដែលលើកឡើងដោយ នួន ជា មានតម្លៃយ៉ាងណាក៏ដោយ ក៏សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះមិនអាចត្រូវបានពិនិត្យឡើងវិញដោយអង្គជំនុំជម្រះសាលាដំបូងដែរ ហើយអង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការក្នុងរឿងនេះទេ[15]"។

## I. ចំណាចពាក់ព័ន្ធនានាឧជម្លោះប្រដាប់អាវុធ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

១៩. ប្រសិនណាអង្គជំនុំជម្រះប្រកាសថា បណ្ដឹងរបស់សហព្រះរាជអាជ្ញាអាចទទួលយកបាន[16] លោក ខៀវ សំផន សន្និដ្ឋានថា សហព្រះរាជអាជ្ញាពុំបានបង្ហាញថាច្បាប់ដែលនៅជាធរមានក្នុងចន្លោះឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ពុំបានតម្រូវឱ្យមានចាំបាច់នូវអត្ថិភាពនៃជម្លោះប្រដាប់អាវុធ នៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។

***គោលការណ៍នីត្យានុកូលភាព***

[15] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី លើសំណើសុំឱ្យដោះលែង "នួន ជា, អៀង ធីរិទ្ធ និង ខៀវ សំផន" ជាបន្ទាន់ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ *ឯកសារតុលាការ* E1/1.1 ទំព័រ ៤៧ ចាប់ពីបន្ទាត់ ៩ ដល់ ២៥ [លេខទំព័រក្នុងប្រតិចារឹកជាភាសាបារាំង] មិនមានគូសបន្ទាត់ពីក្រោមនៅក្នុងឯកសារដើម។

[16] ដោយមិនទាន់គិតពីទឡ្ហីករណ៍ ដែលលើកឡើងក្នុងអញ្ញត្រកម្ម ទាក់ទងនឹងការមិនអាចអនុវត្តបាននូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅអ.វ.ត.ក និងច្បាប់ទំនៀមទំលាប់អន្តរជាតិ ពាក់ព័ន្ធផ្នែកព្រហ្មទណ្ឌ៖ អញ្ញត្រកម្មបឋម កថាខណ្ឌ១៦-១៧ និង ២២-២៤។

២០. សហព្រះរាជអាជ្ញាយល់ឃើញថា "និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានលើកឡើងនៅក្នុងច្បាប់ស្តីពី អវតក មានលក្ខណៈស្របគ្នាទៅនឹងគោលការណ៍នីត្យានុកូលភាព[17]"។ បច្ចុប្បន្ន បញ្ហានេះត្រូវបានព្យួរទុកមួយអន្លើនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយអង្គជំនុំជម្រះសាលាដំបូងបានទុកលទ្ធភាពដល់ភាគីក្នុងការលើកឡើងនូវទឡ្ហីករណ៍របស់ខ្លួនជាលាយលក្ខណ៍អក្សរ នៅក្នុងតំណាក់កាលនៃសវនាការបឋម[18]។ លោក ខៀវ សំផន បានយោងទៅលើទឡ្ហីករណ៍នានាដែលបានលើកឡើងនៅក្នុងអញ្ញត្រកម្មបឋមស្តីអំពីគោលការណ៍នីត្យានុកូលភាព[19]។

## *ច្បាប់ទំនៀមទម្លាប់អន្តរជាតិ*

២១. សហព្រះរាជអាជ្ញាអះអាងថា នីតិទំនៀមទម្លាប់អន្តរជាតិពុំបានតម្រូវឲ្យមានចំណងពាក់ព័ន្ធរវាងជម្លោះប្រដាប់អាវុធ ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តនៅចន្លោះឆ្នាំ ១៩៧៥ និង ឆ្នាំ ១៩៧៩ ឡើយ[20]។ អង្គបុរេជំនុំជម្រះបានធ្វើសេចក្តីសន្និដ្ឋានបញ្ជាស នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនស្តីអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាដំណោះស្រាយ។ លោក ខៀវ សំផន បានយោងទៅលើទឡ្ហីករណ៍ដែលបានលើកឡើងដោយអង្គបុរេជំនុំជម្រះ[21]។ ភាពសមស្របនៃអំណះអំណាងរបស់អង្គបុរេជំនុំជម្រះ ត្រូវបានសង្កេតឃើញថា មានមូលដ្ឋានរឹងមាំតាមរយៈកិច្ចពិភាក្សា និងកិច្ចចរចារនានាក្នុងដំណើរឆ្ពោះទៅបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៨ ដោយនៅពេលនោះ មានការចូលរួមពីសំណាក់គណៈកម្មការនីតិអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលជាច្រើន និងពីបណ្តារដ្ឋជាង ១២០។ និយមន័យដែលបានស្នើឡើងមុនពេលមានសន្និសីទទីក្រុងរ៉ូម បានបង្កប់នូវ

[17] សំណើរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ១៤-១៦។

[18] សេចក្តីណែនាំដល់ភាគីពាក់ព័ន្ធនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ, ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ *ឯកសារតុលាការ* E51/7។

[19] សូមមើល អញ្ញត្រកម្មបឋម, កថាខណ្ឌ៤-១០, ១៦-១៧ និង ២០-២៧។

[20] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៧-២៣។

[21] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ *ឯកសារតុលាការ* D427/1/30 កថាខណ្ឌ៣០៩-៣១០។

បញ្ហាដែលថា តើគេត្រូវដាក់បញ្ចូល ឬមិនគួរដាក់បញ្ចូលនូវសញ្ញាណនៃជម្លោះប្រដាប់អាវុធទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ[22]។ លោក ខៀវ សំផន រំលឹកថា ទង្វើរបស់រដ្ឋទាំងឡាយ គឺជាធាតុផ្សំក្នុងការបង្កើតនីតិទំនៀមទម្លាប់អន្តរជាតិ[23]។

២២. សម្រាប់សហព្រះរាជអាជ្ញា ការណ៍ដែល "អនុសញ្ញាអន្តរជាតិពីរ ដែលបានចូលជាធរមានមុនឆ្នាំ ១៩៧៥ បានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិយ៉ាងច្បាស់ [អំពើប្រល័យពូជសាសន៍ និងរបបប្រកាន់ពូជសាសន៍អាប៉ាថេត] ដោយពុំបានដាក់បញ្ចូលនូវចំណងពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ គឺជាតម្រុយដ៏ខ្លាំងក្លាដែលបង្ហាញថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពុំមែនមិនអាចកាត់ផ្តាច់បានពីជម្លោះប្រដាប់អាវុធដែលប្រព្រឹត្តនៅក្នុងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យនោះឡើយ[24]"។ លោក ខៀវ សំផន យល់ឃើញថាសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាខាងលើពុំមានមូលដ្ឋានតាមផ្លូវច្បាប់ឡើយ ។ នៅឆ្នាំ ១៩៩៣ គណៈកម្មការនីតិអន្តរជាតិបានបកស្រាយថា មានតែឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍អាប៉ាថេត និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេ ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្របតាមច្បាប់អន្តរជាតិ។ ជាក់ស្តែង ឧក្រិដ្ឋកម្មទាំងពីរនេះគ្រាន់តែជាឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងសេចក្តីព្រាងលក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិតែប៉ុណ្ណោះ ប៉ុន្តែពុំមែនជាការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែកនោះទេ[25]។ ជាមួយគ្នានេះ គេអាចសន្និដ្ឋាន

---

[22] United Nations Diplomatic Conference of Plenipotentiaries on the Establishment of an International Criminal Court, 15 juin – 17 juillet 1998, Official Records Volume III, A/CONF.183/13 (Vol.III), page 20 : « 1. For the purpose of the present Statute, a "crime against humanity" means any of the following acts when committed [as part of a widespread [and] [or] systematic commission of such acts against any population]: [as part of a widespread [and] [or] systematic attack against any [**civilian**] population] [committed on a massive scale] [**in armed conflict**] [on political, philosophical, racial, ethnic or religious grounds or any other arbitrarily defined grounds] », non souligné dans l'original.

[23] ឧទាហរណ៍ សូមមើល អញ្ញត្រកម្មបឋម, កថាខណ្ឌ១០។

[24] សំណើរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២២។

[25] របាយការណ៍របស់គណៈកម្មការនីតិអន្តរជាតិស្តីអំពីការងារកិច្ចប្រជុំលើកទី៤៥ របស់ខ្លួន (ថ្ងៃទី ៣ ខែ ឧសភា រហូតដល់ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ១៩៩៣) A/48/10 ទំព័រ១១១៖ "ផ្អែកលើយោបល់របស់ក្រុមការងារ លក្ខណៈវិនិច្ឆ័យទាំងពីរចំណុចធំៗ ដែលសម្រាប់ធ្វើការវាយតម្លៃឧក្រិដ្ឋកម្មដែលបានបង្ហាញនៅក្នុងសន្ធិសញ្ញានានាដូចបានរៀបរាប់នៅក្នុងមាត្រា ២២ [ឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍អាប៉ាថេត និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍] ជាឧក្រិដ្ឋកម្មតាមច្បាប់អន្តរជាតិមាន៖ ក). ដោយហេតុថាឧក្រិដ្ឋកម្ម

បានថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងពីរនេះបង្កើតបានជាឧក្រិដ្ឋកម្មអន្តរជាតិ ហើយពុំមែនឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយអាចត្រូវបានប្រព្រឹត្តនៅក្នុងសម័យកាលសន្តិភាពនោះទេ។ សេចក្តីសន្និដ្ឋាននេះ ត្រូវបានគាំទ្រតាមរយៈខ្លឹមសារនៃកិច្ចពិភាក្សានានាទាក់ទងទៅដល់ការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ជាឧទាហរណ៍ គេអាចអានរបាយការណ៍នៃកិច្ចពិភាក្សារវាងរដ្ឋទាំងឡាយ ស្តីអំពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលគេបានហៅថាជាការប្រុងប្រយ័ត្ន ដោយហេតុថា លក្ខន្តិកៈនៃតុលាការសម្រាប់អតីតយូហ្គោស្លាវីបានលើកឡើងអំពីជម្លោះប្រដាប់អាវុធ"។ "គេបានគូសបញ្ជាក់ថា ទាក់ទងដល់ឧក្រិដ្ឋកម្មទាំងនេះ ពុំមានអនុសញ្ញាណាមួយបានផ្តល់និយមន័យតាមផ្លូវច្បាប់ ដែលត្រូវបានទទួលស្គាល់ជាទូទៅ និងមានលក្ខណៈច្បាស់លាស់ឡើយ" ហើយដែល "ឧក្រិដ្ឋកម្មទាំងនេះមានលក្ខណៈខុសគ្នាអំពីឧក្រិដ្ឋកម្មសង្គ្រាម ត្រង់ចំណុចថាប្រជាជនស៊ីវិលអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មនេះ"[26]។ ចំណងពាក់ព័ន្ធដែលមិនអាចកាត់ផ្តាច់បានរវាងជម្លោះប្រដាប់អាវុធ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានទាញចំណាប់អារម្មណ៍របស់រដ្ឋនីមួយៗឱ្យចោទជាសំណួរឡើង ថាតើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចត្រូវបានប្រព្រឹត្តក្នុងសម័យកាលសន្តិភាពដែរឬទេ[27]។ ការបង្កើតតុលាការ

---

ទាំងនេះត្រូវបានកំណត់និយមន័យដោយសន្ធិសញ្ញា ហើយដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិអាចអនុវត្តនូវច្បាប់សន្ធិសញ្ញាជាមូលដ្ឋានចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចែងដោយសន្ធិសញ្ញា។ ខ). ពាក់ព័ន្ធនិងឧក្រិដ្ឋកម្មដែលត្រូវបានកំណត់និយមន័យ សន្ធិសញ្ញាបានបង្កើតឬមួយប្រព័ន្ធនៃយុត្តាធិការសាកល ដែលប្រព័ន្ធនេះផ្អែកទៅលើគោលការណ៍ *aut dedere aut judicare* (*កាតព្វកិច្ចរបស់រដ្ឋក្នុងការជំនុំជម្រះលើឧក្រិដ្ឋជននៃឧក្រិដ្ឋកម្មអន្តរជាតិ*) ឬមួយលទ្ធភាពសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិក្នុងការជំនុំជម្រះឧក្រិដ្ឋកម្ម ឬមួយករណីទាំងពីរនេះតែម្តង។"

[26] គណៈកម្មាធិការពិសេស សម្រាប់ការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារ A/AC.244/CRP.6/Add.3, ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥ *ឯកសារតុលាការ* E46.1.6។

[27] របាយការណ៍របស់គណៈកម្មាធិការ *ad hoc* សម្រាប់ការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ A/50/22 "រួមបញ្ចូលទាំងរបាយការណ៍មុនៗរបស់តុលាការ Nuremberg និងលក្ខន្តិករបស់តុលាការសម្រាប់អតីតយូហ្គូស្លាវី **មតិផ្សេងគ្នាត្រូវបានបង្ហាញពាក់ព័ន្ធទៅនឹងចម្លល់ដែលថាតើឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងសម័យកាលសន្តិភាព អាចស្ថិតក្នុងប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬទេ?** ក្នុងចំណោមអង្គហេតុថ្មីៗដែលកើតមានឡើងបន្ទាប់ពីតុលាការ Nuremberg និងក្នុងទិសដៅដកចេញនូវសញ្ញាណនៃជម្លោះប្រដាប់អាវុធ ពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ គណៈប្រតិភូមួយចំនួនបានឱ្យសញ្ញាដល់លក្ខន្តិកនៃតុលាការសម្រាប់ប្រទេសរវ៉ាន់ដា និងសេចក្តីសម្រេចដែលចេញដោយតុលាការសម្រាប់អតីតប្រទេសយូហ្គូស្លាវីថ្មីៗនេះ ក្នុងរឿងក្តី Tadic។ ដោយ

ព្រហ្មទណ្ឌអន្តរជាតិ គឺជាផ្លែផ្កានៃការងារស្រាវជ្រាវអស់រយៈពេលច្រើនឆ្នាំ ដោយមានការចូលរួមពីសំណាក់ភាគីជាច្រើន ទាំងភាគីជារដ្ឋ និងភាគីដែលពុំមែនជារដ្ឋ។ តាមរយៈការងារស្រាវជ្រាវទាំងនោះ គេអាចសន្និដ្ឋានបានថា ពុំមាននិយមន័យជាអន្តរជាតិណាមួយត្រូវបានកំណត់សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅចន្លោះឆ្នាំ ១៩៩៣ ដល់ ១៩៩៨ ឡើយ (ជារយៈពេលដែលមានកិច្ចពិភាក្សា) ហើយក៏ពុំមានការកំណត់និយមន័យ ដែលថាចំណងពាក់ព័ន្ធរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅនឹងជម្លោះប្រដាប់អាវុធ មិនត្រូវបានគេចាត់ទុកថាចាំបាច់នោះឡើយ។

***ច្បាប់ស្តីពី អវតក***

២៣. សហព្រះរាជអាជ្ញាបានអះអាងថា ចំណងពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ ពុំត្រូវបានបង្ហាញនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងនៅក្នុងមាត្រា៥ នៃច្បាប់ស្តីពី អវតក ឡើយ[28] ។ លោក ខៀវ សំផន យល់ឃើញថា ប្រសិនណាជាពុំមានចំណងពាក់ព័ន្ធណាមួយត្រូវបានចែងយ៉ាងច្បាស់នៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ផ្ទុយទៅវិញចំណងពាក់ព័ន្ធនោះ កើតមានទៅហើយ។ ជាក់ស្តែង ក្នុងគោលដៅដើម្បីបែងចែកឧក្រិដ្ឋកម្មសង្គ្រាមពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និយមន័យបានបញ្ជាក់យ៉ាងច្បាស់លាស់ថា ការវាយប្រហារត្រូវតែធ្វើឡើង "ទៅលើជនស៊ីវិល" ។ អវត្តមាននៃជម្លោះប្រដាប់អាវុធ បានធ្វើឲ្យការគូសបញ្ជាក់នេះមានលក្ខណៈស្រពេចស្រពិលជាខ្លាំង។

***ភាពដែលអាចដឹងមុន***

---

ឡែក គេក៏បានធ្វើការអះអាងផងដែរថា ឧក្រិដ្ឋកម្មខាងលើ ជាធម្មតា ត្រូវបានប្រព្រឹត្តក្នុងអំឡុងនៃជម្លោះប្រដាប់អាវុធ ហើយជាលក្ខណៈពិសេស ត្រូវបានប្រព្រឹត្តក្នុងសម័យកាលសន្តិភាព។ ហើយថា **អត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងករណីនេះមានលក្ខណៈមិនអាចប្រឆាំងបាន** ដោយហេតុថាចរិតលក្ខណៈផ្ទុយគ្នានៃនិយមន័យដែលមានចែងនៅក្នុងឧបករណ៍ផ្សេងគ្នា ហើយដែលគេត្រូវសិក្សាអំពីបញ្ហាជាមុននោះ។" ពុំមានគូសបន្ទាត់ពីក្រោម នៅក្នុងឯកសារដើមឡើយ។

[28] សំណើរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ១៤។

២៤. សហព្រះរាជអាជ្ញាបានអះអាងថា ជនជាប់ចោទអាចប្រមើលមើលជាមុនដឹងថា ខ្លួនអាចនឹងទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តក្រៅក្របខណ្ឌនៃជម្លោះប្រដាប់អាវុធ[29]។ លោក ខៀវ សំផន បានរំលឹកថា ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បានចាត់ទុកជាបទល្មើស នូវអំពើដែលបង្កជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ជាតិ[30]។ នៅក្នុងខណៈដែលបទល្មើសទាំងឡាយដូចបានចោទប្រកាន់ អាចត្រូវបានផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌកម្ពុជា ដូច្នេះវាជារឿងដែលពុំអាចព្រៀងទុកមុន ដែលថាបទល្មើសទាំងនោះអាចត្រូវបានចោទប្រកាន់តាមរយៈការកំណត់បទចោទផ្សេងទៀត។ មេធាវីការពារក្តីសូមរំលឹកផងដែរនូវទឡ្ហីករណ៍របស់ខ្លួនដែល បានលើកឡើងនៅក្នុងកថាខណ្ឌ ១៦ នៃអញ្ញត្រកម្មបឋមរបស់ខ្លួន[31]។

**ហេតុដូច្នេះ**

១. មេធាវីការពារក្តីសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង មេត្តា៖

- ប្រកាសថា សំណើសុំរបស់សហព្រះរាជអាជ្ញាមិនអាចទទួលយកបាន

- ជាករណីបន្ទាប់បន្សំ បដិសេធសំណើសុំរបស់សហព្រះរាជអាជ្ញា។

[29] សំណើរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ២៤-២៦។

[30] ឧទាហរណ៍ សូមមើល មាត្រា ២០៩, ២១០, ៥០០, ៥០១, ៥០៣ ដល់ ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦។

[31] អញ្ញត្រកម្មបឋម, កថាខណ្ឌ១៦។

E95/3

**រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង**

**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី ស សូវាន | ភ្នំពេញ | |
| | មេធាវី Jacques VERGÈS | ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |